# II ឯកសារបទដ្ឋានក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ១ - សារាចរ

ភ្នំពេញ , ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៣

### សារាចរលេខ ០១ពណ.សរ ស្តីពី ការអនុវត្តន៍របបសេដ្ឋកិច្ចទីផ្សារ

* * * * *

យោងលិខិតលេខ ៥៣៦ សជណ. ពហ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

ក្នុងគោលបំណងអនុវត្តរបបសេដ្ឋកិច្ចទីផ្សាររបស់រដ្ឋាភិបាលអោយមានប្រសិទ្ធភាពនៅក្នុងដំណាក់កាលបច្ចុប្បន្ន ក្រសួងពាណិជ្ជកម្ម សូមធ្វើការណែនាំ ដល់អស់លោក អភិបាលខេត្ត - ក្រុង ដូចតទៅ :

សេដ្ឋកិច្ចទីផ្សារ គឺ ជាសេដ្ឋកិច្ច ដែលយកយន្តការទីផ្សារជាមូលដ្ឋាន ។ ដូចនេះ ដើម្បីរៀបចំសេដ្ឋកិច្ចទីផ្សារនៅកម្ពុជា អោយបានត្រឹមត្រូវ និង ពេញលក្ខណៈនោះ រដ្ឋត្រូវគោរពតាមគោលការណ៍គ្រឹះៗ របស់ទីផ្សារ :

១ - រាល់ថ្លៃទំនិញ ត្រូវកំណត់ឡើង ដោយការស្រុះស្រួលគ្នារវាងអ្នកលក់ និង អ្នកទិញ ។

២ - រដ្ឋត្រូវអនុញ្ញាតអោយមានការប្រកួតប្រជែងដោយសេរី រវាងពាណិជ្ជករ និង ពាណិជ្ជករ ។
ដើម្បីអោយមានការប្រកួតប្រជែងដោយសេរី រដ្ឋត្រូវលើកទឹកចិត្ត អោយមាន ពាណិជ្ជករ ច្រើននាក់ធ្វើអាជីវកម្ម ។

៣ - រដ្ឋត្រូវធានាសេរីភាព ដល់ការធ្វើចរាចរទំនិញ របស់ពាណិជ្ជករ ។
ដើម្បីធានាផលប្រយោជន៍ដល់ប្រជាជន រដ្ឋត្រូវមានវិធានការខ្លះៗ ដូចជា :

ក - រដ្ឋណែនាំអោយអ្នកលក់ទំនិញ ដាក់ផ្លាកថ្លៃទំនិញ របស់ខ្លួនបង្ហាញដល់អ្នកទិញ ។

ខ - រដ្ឋធ្វើការណែនាំនិងត្រួតពិនិត្យគុណភាព រង្វាស់រង្វាល់របស់អ្នកលក់ដូរ អោយបានត្រឹមត្រូវ តាមការកំរិតរបស់ក្រសួងមានសមត្ថកិច្ច ។

គ - រដ្ឋធ្វើអន្តរាគមន៍ ដោយផ្ទាល់ ក្នុងករណីដែលយន្តការទីផ្សារមានភាពមិនប្រក្រតី ។

ក្រសួងពាណិជ្ជកម្មសង្ឃឹមយ៉ាងមាំថា អស់លោកអភិបាលខេត្ត ក្រុងមុខជាខិតខំអនុវត្តសារាចរខាងលើ អោយមានប្រសិទ្ធភាពជាពុំខាន ។

សារាចរនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ហត្ថលេខា និង ត្រា

**ចាំ ហួត**

****

# ធីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម

## ប្រកាស

ភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៣

**ប្រកាសលេខ : ២៥២ ឧក.ប្រក**

រដ្ឋមន្ត្រី ក្រសួង ឧស្សាហកម្ម

****

- យោងព្រះរាជក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី
- យោងអនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី